[COURT LOGO]

# ការជូនដំណឹងជាផ្លូវការពីតុលាការកំពូល

**(Official Notice from the Supreme Judicial Court)**

អាស័យដ្ឋាន 1 ឧសភា 9, 2017
អាស័យដ្ឋាន 2
អាស័យដ្ឋាន 3

ជូនចំពោះ ____________________:

ខ្ញុំជាចៅក្រមម្នាក់នៃតុលាការកំពូលដែលជាតុលាការខ្ពស់បំផុតនៅក្នុងរដ្ឋម៉ាស្សាជូសេត្ស៍។ ខ្ញុំកំពុងតែសរសេរមកជំរាបលោក-អ្នកឱ្យបានជ្រាបថា **តុលាការនេះបានលុបចោលនូវការផ្តន្ទាទោសមួយចំនួនប្រឆាំងនឹងលោក-អ្នក**។ ការផ្តន្ទាទោសដែលត្រូវបានលុបចោលនោះត្រូវគេបង្ហាញនៅក្នុងទំព័រដែលដាក់ភ្ជាប់មកជាមួយ តាមឈ្មោះតុលាការ, លេខសំណុំរឿង, ចំនួនករណី, និងការអធិប្បាយពីការចោទប្រកាន់។

**ហេតុអ្វីបានជាតុលាការលុបចោលនូវការផ្តន្ទាទោសទាំងនេះ?**
មានគីមីវិទូម្នាក់ឈ្មោះ អាន្នី ឌូខាន (Annie Dookhan) បានប្រព្រឹត្តិនូវអំពើខុសឆ្គងយ៉ាងធ្ងន់ធ្ងរពាក់ព័ន្ធនឹងការងាររបស់គាត់នៅឯមន្ទីរពិសោធន៍គ្រឿងញៀនរបស់រដ្ឋ។ សំណុំរឿងរបស់លោក-អ្នកគឺជាករណីមួយនៃករណីដទៃទៀតដែលបានរងផលប៉ះពាល់ដោយទង្វើរបស់លោកស្រី **Dookhan**។ ដោយសារហេតុនេះហើយ ការិយាល័យរដ្ឋអាជ្ញាតំបន់បានសម្រេចចិត្តលុបចោលជាអចិន្ត្រៃយ៍នូវការផ្តន្ទាទោសទាំងនោះ។ តាមពាក្យច្បាប់គឺមានន័យថា លុបចោល "ដោយមានការលំអៀង"។ នេះគឺជាការសម្រេចចុងក្រោយបំផុត។ វាមានន័យថា រដ្ឋអាជ្ញានឹងមិនអាចបន្តការចោទប្រកាន់ដូចគ្នានេះ ប្រឆាំងនឹងលោក-អ្នកក្នុងករណីនេះឡើយ។

**តើមានអ្វីកើតឡើងបន្ទាប់ទៀត?**
លោក-អ្នកប្រហែលជាបានទទួលសំបុត្រមួយអំពីករណីរបស់លោក-អ្នកកាលពីខែកញ្ញា។ សំបុត្រនោះបានឱ្យដឹងថា លោក-អ្នកអាចទៅតុលាការដើម្បីដេញដោលពីការផ្តន្ទាទោសរបស់លោក-អ្នក។ **ឥឡូវនេះ លោក-អ្នកមិនចាំបាច់ចាត់វិធានការអ្វីដើម្បីដេញដោលការផ្តន្ទាទោសដែលត្រូវបានគេរាយក្នុងទំព័រដែលដាក់ភ្ជាប់មកជាមួយនោះទេ។ សំណុំរឿងអស់នោះត្រូវគេបានលុប និងជំរះចោលអស់ហើយ។**

ក្នុងរយៈពេលប្រហែលជាពីរទៅបីខែ បញ្ជីបទឧក្រិដ្ឋរបស់លោក-អ្នកនឹងត្រូវបានគេផ្តល់នូវទិន្នន័យថ្មីដើម្បីលុបចោលនូវការផ្តន្ទាទោសនោះ។ ការលុបចោលនូវការផ្តន្ទាទោសនោះពីបញ្ជីបទឧក្រិដ្ឋរបស់លោក-អ្នកអាចផ្តល់អត្ថប្រយោជន៍សំខាន់ៗ ដល់លោក-អ្នកទាក់ទងទៅនឹងការងារ, ការរកជួលផ្ទះ, រឿងអន្តោប្រវេសន៍ និងអ្វីៗ ច្រើនទៀត។

ទោះជាយ៉ាងណាក៏ដោយ បញ្ជីបទឧក្រិដ្ឋរបស់លោក-អ្នកមិនទាន់ត្រូវបានគេបិទផ្និតនោះទេ។ លោក-អ្នកអាចរកឃើញព័ត៌មានបន្ថែមទៀតអំពីការបិទផ្និតបញ្ជីបទឧក្រិដ្ឋរបស់លោក-អ្នកនៅ www.masslegalhelp.org/cori.

ដូចគ្នានេះផងដែរ, លោក-អ្នកប្រហែលជាអាចមានការផ្តន្ទាទោសដទៃផ្សេងទៀតក្នុងករណីជាមួយគ្នាដែលមិនត្រូវបានរងផលប៉ះពាល់ដោយកំហុសវិជ្ជាជីវៈរបស់លោកស្រី Dookhan ឡើយ។ ការផ្តន្ទាទោសណាដែលមិនត្រូវបានគេរាយនៅក្នុងទំព័រភ្ជាប់មកជាមួយនេះទេ នឹងនៅតែមាននៅលើកំណត់ត្រាបទឧក្រិដ្ឋរបស់លោក-អ្នកដដែល។

បើលោក-អ្នកមានសំណួរអ្វីមួយពីសំបុត្រនេះ លោក-អ្នកអាចទូរស័ព្ទទៅបណ្តាញបន្ទាន់ពីករណីDookhan ដែលចាត់ចែងដោយគណៈកម្មាធិការសំរាប់សេវាកម្មមេធាវីសាធារណៈដែលជាស្ថាប័នការពារចុងចោទក្នុងរដ្ឋម៉ាស្សាជូសេត្ស៍ តាមលេខ **888-999-2881** ឬនៅគេហទំព័រ **www.mass.gov/courts**។

ដោយសេចក្តីរាប់អាន,

[ហត្ថលេខា-អេឡិចត្រូនិក]

ចៅក្រមនៃតុលាការកំពូល